# អតីតកាល

គេចាកចេញទៅហើយ។

នៅក្រោមពន្លឺព្រះចន្ទតែមួយ តើគេក៏កំពុងនឹកមករកនាងដែរទេ?សន្យាគិតមមៃទាំងក្តីទុក្ខសោកសៅ។

នាងលែងយំហើយ ព្រោះរយៈពេលដ៏វែងដែលនាងបានរង់ចាំគេ ចុងក្រោយគេមកបង្ហាញខ្លួន ក្នុងនាមជាប្អូនថ្លៃ?

ជាច្រើនលើកច្រើនសានាងចង់ដឹងថាកន្លងមកមានរឿងអ្វីកើតឡើងចំពោះគេហេតុអ្វីបានជាគេមិនទៅរកនាង។

តើគេខឹងចិត្តរឿងអ្វីបានជាផ្តាច់ចំណងស្នេហានេះទាំងទទឹងទទែងហើយចុងក្រោយសូម្បីនាងចង់ជួបក៏មិនបាន? របួសលើមុខគេមែនទេ?

ចុះហេតុអ្វីគេបដិសេធថាមិនស្គាល់នាង?

អាការៈរបស់គេមិនមែនធ្វើពើទេ សន្យាដឹងច្បាស់គេ គឺមានសភាពហាក់បីដូចជា មិនដឹងខ្លួនឯងជាអ្នកណា មិនដឹងសូម្បីតែថាពីមុនមានរឿងអ្វីខ្លះបានកើតឡើងក្នុងជីវិតគេ។

អ៊ីចឹងហេតុអ្វីគេវិលមកកម្ពុជាវិញ?

បើបំណាច់នឹងបដិសេធនាង១៤លើកទៅហើយ ហេតុអ្វី ម្សិលមិញគេបែរជាកើតគំនិតអនុញ្ញាតឱ្យនាងចូលទៅ?

យប់នេះទៀតសោត.....រឿងមិនប្រក្រតីរវាងពួកយើងហាក់បានចាប់ផ្តើមឡើងហើយ...

Lorenzo  នេះជាលើកទីមួយដែលបងសម្លឹងរកបន្ទប់ខ្ញុំ។

បងជិតរៀបការជាមួយប្អូនស្រីខ្ញុំហើយ ថ្ងៃនេះក៏ជាលើកដំបូងដែលយើងបានជួបគ្នាបន្ទាប់ពីបែកគ្នាអស់ពេល៥ឆ្នាំ។ ព្រះចន្ទអើយ តើគេពិតជានៅនឹកឃើញខ្ញុំឬភ្លេច?

សន្សឹមៗ នាងរំឭកមកវិញនូវអនុស្សាវរីយ៍ផ្អែមល្ហែម.....

៥ឆ្នាំមុន....

តំបន់ជម្រាលភ្នំមួយព្រំប្រទល់រវាងខេត្តកោះកុងនិងកំពង់ស្ពឺ។ ព្រៃក្រាស់ អ័ព្ទត្រជាក់។ ទីកន្លែងកំណើតស្នេហ៍ដែលនារីស្មោះត្រង់ម្នាក់បានជួបប្រសប់នឹងបុរសខ្វាត់ព្រាត់។

ទោះបីជាពេលវេលាកន្លងទៅយូរប៉ុនណា នាងនៅតែមិនដែលបំភ្លេច ល្ងាចដ៏មានអត្ថន័យមួយនោះបានឡើយ។

ស្រមោលស្រអ័ព្ទនៃព្រះទិនករហៀបអស្តង្គត រំលត់ទ្វីបលោកទៅក្នុងសន្ធិយាមិនប្រើពេលយូរប៉ុន្មាន ចុះហេតុម្តេចបានជាចង់បំភ្លេចមនុស្សម្នាក់ឱ្យបាន វាពិបាកយ៉ាងនេះ?

អតីតកាលវិលវិញ....គ្រប់យ៉ាងដូចនៅថ្មីៗ ថ្ងៃដែលគេរងរបួស ហើយគេបានមកដល់ដូចទេពនិម្មិត ....កាលណោះ.....

ថ្ងៃលិចទាំងស្រុងហើយ ប៉ុន្តែនាងទើបនឹងចាប់ផ្តើម ចម្អិនអាហារ។

ទីនេះមិនមែនជា «ផ្ទះអនាគត» ដែលនៅក្បែរព្រៃទេ ប៉ុន្តែជាផ្ទះរបស់ស្រីតូចឈ្មោះសន្យា

ដណ្តាំអាហារផង បើកបង្អួចផ្ទះបាយផង ដូច្នេះនាងអាចនឹងរីករាយសម្លឹង ភាពស្រស់ស្រាយនៃថ្ងៃទេសភាពស្រមោលទិនករសេសសល់ លើជម្រាលបៃតងលឿង។

រំពេចនោះ នាងពិតជាមើលឃើញមនុស្សម្នាក់រត់ ហើយក្រោយមកគេនោះដួលស្រុញបាត់។ ទោះបីអ្វីៗហាក់មិនច្បាស់ តែនាងចង់ដឹងណាស់ថានោះជា អ្វីទៅ?

នាងរត់សំដៅគោលដៅហើយចុះតាមជម្រាលភ្នំដែលខ្លួនធ្លាប់ស្គាល់យ៉ាងស្និទ្ធ។

«មនុស្សធ្លាក់មែនហើយតែគេនៅឯណា?»

នាងគិតហើយក៏ដំឡើងសំឡេងស្រែកសួរៈ

«មានអ្នកណានៅក្រោមអត់ហ្នឹង?»

បរិយាកាសហាក់ព្រងើយកន្តើយនឹងការស្រែកហៅរបស់នាង ឮតែសំឡេងខ្លួនឯងខ្ទរត្រឡប់មកវិញល្វើយៗ។

ពិនិត្យសព្វគ្រប់កើត លិច ជើង ត្បូងមិនឃើញមានអ្វីប្លែក ស្រីតូចបែរឃើតៗត្រឡប់ក្រោយបម្រុងនឹងវិលទៅវិញ ព្រោះរាត្រីកាលក៏ត្រៀមនឹងពន្លិចទីនេះទៅក្នុងភពងងឹត តែនៅពេលដែលនាងដើរបានប៉ុន្មានជំហាន អ្វីមួយជាប់ទើររវិចលើមែកឈើ បង្ខំនាងឱ្យភ្ញាក់ព្រើត។

ទីនេះមិនដែលមានអ្នកណាមកភ្លេចអាវអ្វីនឹងមែកឈើថ្មើរណោះ?

ណាមួយមើលពីចម្ងាយ ដូចជាមិនមែនតួអាវទាំងស្រុងផងបណ្តាលឱ្យនាងមានការសង្ស័យជាខ្លាំង។

ស្រីតូចរត់សំដៅទៅក្បែរប៉ប្រះព្រៃ។ នៅក្រោមភាពងងឹត៩០ភាគរយនៃអន្ធការ អ្វីមួយខ្មៅស្លុងពិតជាសំងំច្រងាង នៅទីនោះ ប្រមាណជា១០ម៉ែត្រប៉ុណ្ណោះពីមុខនាង។

រាងជាមនុស្សដេក ហើយសន្យាប្រាកដចិត្តណាស់ថា ជាមនុស្សដែលនាងបានឃើញធ្លាក់។

ស្រីច្រមក់ដើរសន្សឹមៗ ចូលទៅ.....

« នែ៎! ពូ? ពូ?»

គ្មានចម្លើយ តែគេហាក់កម្រើកខ្លួនលាយសំឡេងថ្ងូរ។ ចិត្តនាងអាណិតអាសូរច្រើនជាងភ័យរន្ធត់។ សន្យាដឹងថា បុរសពុំមែនជាអ្នកភូមិ ដែលខ្លួនធ្លាប់ឃើញ ហើយគេប្រាកដជារត់គេចពីអ្វីមួយមិនស្គាល់ទិសតំបន់បានជាត្រូវដួលធ្លាក់សល់សំណល់ដៃអាវរហែក បក់រវិចកៀងជាប់នឹងប្រកៀកឈើក្បែររាងកាយ។

«ពូឯងមានរឿងអី!»

ចម្លែកណាស់គេស្រាប់តែមានកម្លាំងពីណាមកទេក៏ស្ទុះក្រោក។ ទោះបីពន្លឺពេលនេះមើលឃើញគ្រប់យ៉ាងមិនច្បាស់ តែនាងឃើញរាងកាយធំខ្ពស់របស់នាយ និងក្លិនទឹកអប់ដ៏ទាក់ទាញស្រាលស្ទើកអណ្តែតអណ្តូងចិត្ត។ បុរសនេះតាមពិតជាប្រុសស្អាតម្នាក់ក្នុងបេះដូងលោតភ្លឹករបស់នាង។

គេមិនរវល់នឹងកែវភ្នែកម៉ក់ៗនៃស្រីតូចដែលភាន់ភាំងនិងសម្រស់ខ្លួនឡើយ។ ប្រុសស្អាតចាកចេញចោលនាងទាំងមិននិយាយស្វាគមន៍សូម្បីតែមួយម៉ាត់ តែគេដើរបានប៉ុន្មានជំហានប៉ុណ្ណោះក៏ដួលរលេទៅវិញដូចដើម។

នៅពេលដែលម្ចាស់ផ្ទះអនាគត កំពុងចំហមាត់ធ្លុង នាងបានសម្គាល់ឃើញថាបុរសនេះ ហាក់ត្រូវរបួសប្រឡាក់អាវខាងស្តាំ ជោគខ្មៅ មិនដឹងជាញើស ឬឈាមឱ្យប្រាកដ ជាមួយនោះ ដៃគេដែលបាត់ដៃអាវម្ខាងហាក់បីដូចជាកម្រើកមិនសូវបានល្អ។

គេដេកស្ងៀម ដង្ហើមដង្ហក់ នៅតែប្រឹងស្រវាក្រោកគ្រាន់តែក្រោកមិនរួចត្រឹមត្រូវ។

សេចក្ដីមេត្តាករុណាដែលកប់ជ្រៅ ក្នុងសន្ដានចិត្តនារីតូចក៏បានបញ្ចេញឥទ្ធិពលបាំងបាត់ភាពងឿងឆ្ងល់របស់នាង។ ទោះគេមើលទៅសោះកក្រោះមិនសូម្បីសម្លឹងមុខនាងដែលមានបំណងល្អ តែនារីនេះនៅតែចង់ជួយគេ។

«បងឯងកម្រើកធ្វើអី? ចាំខ្ញុំជួយ»

គេនៅផ្ទឹងពេលនាងអោនមកកៀកនឹងកែវភ្នែក។ នារីនេះមានសម្រស់ធម្មជាតិ ដ៏អាថ៌កំបាំង ភ្ជាប់ជាមួយសំឡេងស្រទន់ពីរោះបង្ហាញនូវ ចរិតដ៏ត្រង់ទៅត្រង់មករបស់នាង។

«អ្នកណាធ្វើបាបបងឯង?»

សម្ដីនាងធ្វើឱ្យគេនឹកឃើញឡើងវិញដល់គ្រោះថ្នាក់ដែលទើបប្រទះជាដំបូងក្នុងជីវិត។ រហូតដល់ពេលនេះ អ្នកណាម្នាក់នៅពីក្រោយការទិញជីវិតរបស់ខ្លួន គេក៏មិនដឹងផង ចុះទម្រាំបើខ្លួនឈឺស្ពឹកក្រោកមិនបាន?

«ខ្លួនឯងជាអ្នកណា?»

គេសួរនាងវិញតិចៗទាំងជ្រួញចិញ្ចើមឈឺចាប់ពេលដែល កម្រើកមាត់និយាយ។

«បំពង់កបងឯងហូរឈាម?»

នាងនិយាយដោយផ្លាស់ទឹកមុខទៅជារន្ធត់សោកសៅ។ នរៈស្រវាយកម្រាមប៉ះទីដែលឈឺពើត។ វាជារបួសសើស្បែកតែវាក៏មិនមែនស្រាលៗដែរ។

នាងអោនមកគ្រាហ៍នាយឡើង។

«យកខ្ញុំទៅណា?»

គេសួរតិចៗទាំងអស់សង្ឃឹម។

ស្ថានភាពនេះ បើឱ្យពួកមនុស្សអាក្រក់រកឃើញ តើមានមធ្យោបាយអីនឹងតស៊ូទៀត?

ស្នូរសត្វបក្សាបក្សីរិលរកទ្រនំយំរំពងធ្វើឱ្យបរិយាកាសរឹតតែស្រងេះស្រងោច។ ក្នុងកែវភ្នែកស្រីតូចលេចចេញនូវតំណក់ទឹកថ្លា រលីងរលោង៖

«ខ្ញុំជួយបងឯងហ្នឹងណ៎ា!»

រស្មីព្រិចៗនៃទឹកនេត្រាស្រីស្អាតចាំងផ្លេកៗ ជ្រែកភាពងងឹត ធ្វើឱ្យបេះដូងតារាធ្លាក់ចាកមេឃ ទៅជាទន់ច្របល់។ គេសួរទាំងក្បាលកើយលើរង្វង់ដៃនាងបីត្រកង៖

«យើងមិនដែលស្គាល់គ្នា យំធ្វើអី?»

នាងដកដង្ហើមលាន់ស្នូរសម្បោរគគ្រូក ហើយឆ្លើយ៖

«ខ្លួនជិតស្លាប់ហើយនៅមិនដឹងទៀត!»

Lorenzoចងចិញ្ចើមហួសចិត្ត៖

«អ្ហះ? .....អូខេ ! មិនបាច់ជួយក៏បាន បើគង់តែដាក់បណ្តាសាដដែល!»

នាងសម្រួលឥរិយាបថព្រោះជ្រុលនិយាយមិនបានគិត តែនាងពិតជាមានភាពអាណិតអាសូរនាយតាមកែវភ្នែកមិនដាច់ស្រេចសោះ។

«ខ្ញុំមានថ្នាំឃាត់ឈាមនៅផ្ទះ!»

ថាចប់ស្រីស្អាតប្រឹងត្រកងបុរសនេះក្រោកទាំងត្រដាបត្រដួស។

គេប្រឹងតស៊ូក្រោកជាមួយនាង រហូតដល់ឈរបានទាំងស្រែកថ្ងូរឈឺចាប់នឹងមុខរបួស។

«ត្រូវត្រង់ណាខ្លះ!»

នាងសួរទាំងទទួលអារម្មណ៍ហាក់ឈឺជំនួសនាយ ប៉ុន្តែបុរសនេះមិនឆ្លើយ បែរជាព្យាយាមឃាត់មិនឱ្យនាងដើរបន្តទៅមុខ។

គេសំកាំងមិនព្រមទៅហើយនិយាយខ្សឹបៗ៖

«សន្យាបានទេ?»

«ម៉េចស្គាល់ឈ្មោះខ្ញុំ?»

គេមិងមាំងព្រោះមិនដឹងឡើយថា នាងឈ្មោះ«សន្យា»។

«ខ្ញុំឱ្យខ្លួនឯងសន្យា!»

«ឱ្យអីខ្ញុំ?»

គេហាក់ធុញទ្រាន់ ណាឈឺរបួស ណានឿយចិត្តនិងនាងច្រមក់ ប៉ុន្តែភ្នែកនាងខ្មៅក្រឹបទំនងជាមនុស្សមានចិត្តថ្លៃមស្មោះត្រង់ ទើបបណ្ដាលចិត្តគេឱ្យតស៊ូពន្យល់៖

«ខ្ញុំឱ្យខ្លួនឯងជួយ តែត្រូវព្រមសន្យាថាមិនប្រាប់អ្នកណាទាំងអស់!»

នារីនេះយល់ពីអ្វីដែលគេកំពុងតែចង់មានន័យហើយ។ នាងនៅស្ងៀមព្រោះមិនដែលមានមនុស្សឯណាបានគេជួយហើយដាក់លក្ខខណ្ឌទៀតនោះទេ។

នាងក្រញូវ មិនមាត់ បុរសនេះផ្ទួនបន្ថែម៖

«អ្នកណាក៏ដោយ!»

គេបញ្ជាក់ធ្វើឱ្យនាងកាន់តែធុញទ្រាន់។ ទោះយ៉ាងណារាងកាយគេហាក់ដូចចង់ញាក់ទៅតាមកម្រិតអាកាសធាតុដែលប្រែប្រួលរហ័សនៃតំបន់ព្រៃភ្នំ ហើយគេចាប់ផ្ដើមឡើងកម្ដៅពីខាងក្នុង។ នាងប្រញាប់ប្រញាល់ដកអារម្មណ៍ចេញពីការអង្គាសចិត្តគ្នា ហើយកំណត់សុខុមាលភាពនាយជាអាទិភាពវិញ។

«តោះទៅ!»

នាងបណ្ដើរបុរសនេះទៅចំពេលដែលគេចាប់ផ្ដើមងងឹតមុខបន្តិចៗម្ដង។

នាងបម្រុងថា នាំគេទៅផ្ទះ ដឹងអីសម្ដីគេមុននេះហាក់រំឭកនាងឱ្យគោរពពាក្យដែលគេស្នើសុំ។

«មនុស្សនេះឫកធំណាស់! មុនសន្លប់ឆ្លៀតបញ្ជាខ្ញុំបានទៀត!»

ប្រុសស្អាតលែងមាត់ក បណ្ដោយឱ្យនាងបណ្ដើររហូតដល់ខាងលើហើយខ្សឹបផ្ដាំ។

«នៅឱ្យស្ងៀម! បើមិនចង់ឱ្យអ្នកណាឃើញ ត្រូវទៅឆ្ងាយបន្តិច! ចាំហ្នឹងហើយខ្ញុំទៅយកម៉ូតូ!»

បុរសត្រូវបាននាងដាក់អង្គុយលើដង្គត់ឈើ ប្របមាត់ផ្លូវ ហើយមិនយូរប៉ុន្មាននាងវិលត្រឡប់មកវិញជាមួយម៉ូតូដែលធ្លាប់បញ្ជិះប្រធាននិស្សិតឈុនរាជ។

«តោងខ្ញុំឱ្យជាប់! ខំឡើងណា!»

ផ្ទះអនាគត នៅឆ្ងាយប្រមាណជាងមួយគីឡូពីភូមិនៃប៉ប្រះនឹងមាត់ព្រៃ។

«ម៉ូតូខ្ញុំមួយរយៈនេះដឹកអ្នកភ្នំពេញញឹកដល់ហើយ!»

គេបើកភ្នែកមកវិញភ្លាមទោះងងឹតមុខបែបណាក៏ដោយ។ សមាសភាពខ្លួនជារឿងដែលត្រូវពិបាកចិត្ត គេសួរខ្សោយៗ៖

«ម៉េចដឹងខ្ញុំអ្នកភ្នំពេញអ្ហះ?»

«ក្លិនទឹកអប់បងឯង សាច់ឈាមបងឯង!»

នាងឆ្លើយវិញធ្វើហី មិនរវល់និងការភ័យបារម្ភដែលកំពុងមានសន្ទុះកើនឡើងក្នុងចិត្តនាយអ្វីបន្តិចឡើយ។

នរៈរូបនេះកំពុងតស៊ូនិងការឡើងកម្តៅរាងកាយក្បាលឈឺស្ទើរបែកភ្នែកព្រិលស្រវាំងតែគេនៅខំប្រើដង្ហើមតិចតួចនេះ រិះរកមធ្យោបាយ។ ចុងក្រោយគេនៅតែគ្មានធ្វើអ្វីបានក្រៅពីនិយាយជាមួយនាងដាច់ៗដោយផ្តេកមុខលើស្មាស្រីតូច៖

«ខ្លួនឯងសន្យារួចហើយ ថាមិនប្រាប់អ្នកណាពីរឿងបង!»

នារីដៀងភ្នែកមកមើលគេ។ ចិត្តនាងរិះគិត តើបុរសនេះមកពីណា ត្រូវអ្នកណាតាមបានជាគេចចេសរឿងលាក់ការណ៍ម្ល៉េះសូម្បីតែ មុនពេលបិទភ្នែកស្លុងទៅ។

«បងឯងឈ្មោះអី?»

គ្មានចម្លើយ។

នាងក៏លែងសួរបន្ថែមល្បឿន តម្រង់សាលាព្រោះដឹងថាគេលែងស៊ូបានហើយ។

**Lorenzo ជាអ្នកណា?**

នៅក្រោមពន្លឺដួងព្រះខែតែមួយ  Lorenzoចាកចេញពីផ្ទះពិនណាកាលណា គេមិនបានទៅផ្ទះទេ គឺអង្គុយសំកុកនៅ SkyBarម្នាក់ឯង។

ច្រើនឆ្នាំមកហើយ ដែលគេគេងមិនលក់ឱ្យលើសពី៣ម៉ោងក្នុងមួយយប់សោះ។ គេមិនដឹងថាខ្លួនឯងមានរឿងរញ៉េរញ៉ៃអ្វីខ្លះនោះទេនៅក្រោយការដឹងខ្លួនមកវិញបន្ទាប់ពីគ្រោះថ្នាក់ចរាចរណ៍មួយ។

ឪពុកម្ដាយបានត្រឹមទទួលស្គាល់ថា ការខំប្រឹងរំឭករកអតីតកាលមកវិញជារឿងដែលធ្វើឱ្យសុខភាពគេកាន់តែមានបញ្ហា ម្ល៉ោះហើយគ្រប់គ្នាលើកទឹកចិត្តឱ្យគេរស់នៅផ្ដោតលើអនាគតជាជាងស្វែងរករឿងចាស់។

នៅក្រោមផ្ទៃមេឃត្រកាលនៃវាយោកុម្ភៈស្រស់សោភា ចិត្តនរៈបែរជារងា គ្មានកោះត្រើយ។ អ្វីដែលចម្លែក គឺក្រសែភ្នែកនៃមនុស្សស្រីម្នាក់នោះ សម្ដីនាង ដៃនាងដែលច្រានទ្រូងនាយ ហេតុអ្វីបញ្ជូនមកនូវថាមពលម្យ៉ាង ពិបាកកាត់ផ្ដាច់ថាមិនធ្លាប់ស្គាល់គ្នា។

នាងមើលទៅមិនវិកលចរិតទេ មនុស្សស្រីដែលមើលទៅគោរពអ្នកដទៃគោរពខ្លួនឯង នាងម្ដេចនឹងមកបង្កើតរឿងឡើងឱ្យប្អូនស្រីបង្កើតខ្លួនឯងឈឺចាប់?

គេឈ្ងោកមើលអេក្រង់ទូរសព្ទពេលដែលលោតសារមកដល់។

«គឺម៉ាក់ណ៎ាកូន! ម៉ាក់ខលទៅច្រើនលើក អត់អ្នកទទួល! រវល់ធ្វើអីហ្នឹងកូន?!»

អ្នកម្ដាយប្រាកដជាមនុស្សដែលគួរឱ្យទុកចិត្តបំផុតហើយក្នុងពេលដែលយើងកំពុងស្ថិតក្នុងសភាពតឹងចិត្តចប់អារម្មណ៍។

Lorenzoគិតពីរឿងនេះបានជាគេអោនមកឈ្ងោកសរសេរសារតបៈ

«ម៉ាក់! ពិម្សិល កូនបានជួបស្រីម្នាក់! គេនោះឈ្មោះ វីរីណា អូទេ គេហៅខ្លួនគេថា សន្យា!គេមិនបាននិយាយអ្វីច្រើន តែគេហាក់ដូចជាពិបាកចិត្តធ្ងន់ណាស់ពេលឃើញកូន និងរបួសលើមុខកូន! ពេញមួយថ្ងៃនេះ កូនមានអារម្មណ៍ដក់រូបគេជាប់ក្នុងការគិត!

មួយដង្ហើមណាក៏កូនគិតពីគេ ! កូនមិនដឹងថាហេតុអី?គេជាអ្នកណាទៅម៉ាក់? »

ម្ដាយនៅស្ងាត់ស្ងៀមទោះបីជាកំពុងអនឡាញ។

តើគ្រប់គ្នាដឹងរឿងអ្វីខ្លះទាក់ទងនឹងនាងបានជាម្នាក់ៗហាក់មានប្រតិកម្មចម្លែក? តែម៉ាក់ គឺជាម្ដាយក៏ជាស្រីម្នាក់ដែលកូនៗលើលោកនេះទុកចិត្តទុកថ្លើម ជាងគេ មិនសមថាម៉ាក់ក៏មិនជួយកូន ក្នុងការស្វែងរកអតីតកាលឱ្យខ្លួនឯងដែរទេមែនទេ?

គេគិតបណ្ដើរសរសេរទៅកាន់គាត់ទន្ទឹមគ្នា។

គាត់តបមកវិញដែរៈ

«Lorenម៉ាក់នៅអាមេរិករហូតមក! ម៉ាក់មិនដឹងទេថា រឿងអ្វីខ្លះបានកើតឡើងរវាងកូននិងអ្នកផ្សេង! កាលពីមុនមកទេកូនប្រុស! សូម្បីជាមួយពិនណាគូដណ្ដឹងកូន! ម៉ាក់គិតថា កូនគិតច្រើននាំតែប៉ះពាល់សុខភាព រយៈពេលនេះម៉ាក់ចង់ឱ្យកូនទទួលបានសុភមង្គល ហើយរស់នៅស្ងប់ចិត្តផ្ដោតលើអនាគតប្រសើរជាងណ៎ាLoren ពីរអាទិត្យទៀតម៉ាក់និងប៉ាទៅដល់ភ្នំពេញហើយ!មង្គលការនេះ គឺជារឿងល្អបំផុតមួយសម្រាប់កូននិងគ្រួសារយើង!ម៉ោងនៅភ្នំពេញយប់ជ្រៅហើយ សម្រាកទៅដើម្បីម៉ាក់ ណ៎ា!»

«កូនចង់ពន្យារមង្គលការនេះសិនអ្នកម៉ាក់!»

អ្នកស្រីភីណាដែលនៅឯនាយទំនងជាស្លុតចិត្តណាស់ជាមួយឃ្លាចុងក្រោយនេះ ព្រោះលោកដឹងហើយថាកូនប្រុសសំណព្វមិននិយាយលេង គេជាមនុស្សនិយាយដឹងនិយាយ ធ្វើដឹងធ្វើពេលនេះទៀតសោត ដល់ថ្នាក់ចង់រំសាយមង្គលការ តើមនុស្សស្រីដែលគេជួបកាលពីព្រឹកមិញជាអ្នកណា ? ហេតុអ្វីនាងមានឥទ្ធិពលថ្នាក់នេះមកលើជីវិតគេ?

«កូនចង់រកខ្លួនឯងឱ្យឃើញសិន មុនពេលទៅពាក់ព័ន្ធជាមួយអនាគតអ្នកដទៃ!»

គឺគេចង់សំដៅលើពិនណាឬអ្នកណា?

អ្នកស្រីសួរខ្លួនឯងទាំងពិភាល់មិនស្រណុកចិត្តសោះឡើយ។ កូនប្រុសម្នាក់នេះ ចេញពីផ្ទះ ហើយជួបរឿងមិនល្អជាច្រើនលើកច្រើនសាមកហើយ បើមិនឱ្យម្ដាយម្នាក់នឹកបារម្ភតើសមដែរទេ?

អ្នកស្រីប្រញាប់តបមកវិញ៖

«Loren ចុះក្រែងកូនយល់ព្រមជាមួយមង្គលការនេះហើយ???ពិនណាជាមនុស្សស្រី គេមិនអាចទទួលយកការស្នើសុំនិងពន្យារវិញទទឹងទទែងអ៊ីចឹងបានទេកូន! អូខេណ៎ាកុំគិតពេក ម៉ាក់បារម្ភ! បើចាំបាច់ ម៉ាក់ឡើងទៅស្រុកខ្មែរជួបកូនដើម្បីជជែកគ្នាវិញ!កុំទាន់សម្រេចចិត្តអីឆេវឆាវ ទីនោះជាស្រុកខ្មែរខាងមនុស្សស្រីគេងាយរងគ្រោះព្រោះតែរឿងខូចមុខមាត់!»

«កូនអាចពន្យល់ពីនណាបាន! កូនមិនមែនមិនរៀបការទេម៉ាក់ តែគ្រាន់ចង់ពន្យារ ដោយសារមូលហេតុសុខភាព!»

ម្ដាយមិនសរសេរមកទៀតបានន័យថាលោកកំពុងតែព្រួយបារម្ភរឹតខ្លាំង។

«កូនសម្រាកហើយ ជម្រាបលាអ្នកម៉ាក់!»

តែគេបាននិងកំពុងកុហក ។ គេមិនបានសម្រាកទេព្រោះកុំព្យូទ័រគេលោតមកនូវសារអ្នកផ្សេង ដែលជាមនុស្សដ៏ជិតដិតរបស់គេ....

«អ្នកប្រុសLoren! យូរណាស់ហើយមិនដែលឃើញអ្នកប្រុសសរសេរមក! ខ្ញុំភ្ញាក់ផ្អើលណាស់!ម៉ោងប៉ុន្មានហើយនៅស្រុកខ្មែរ? តាមថាកណ្ដាលអាធ្រាត្រហើយ អ្នកប្រុសគិតសុខភាពផងឆាប់សម្រាកទៅ....!»

ម្នាក់នេះសរសេរមកច្រើនក្នុងពេលតែមួយ ហាក់បីដូចជាបង្ហាញនូវក្ដីឈឺឆ្អាលខ្លាំងបញ្ជាក់ថា ខ្លួនមិនបានរកមនុស្សខុសទេ។

តែនរៈយើងតបវិញខ្លីៗ៖

«បងវឌ្ឍនៈ !ខ្ញុំចង់ជួបបងណាស់!»

យូរមកហើយ ជំនួយការវឌ្ឍនៈមិនដែលបានទទួលសារពីចៅហ្វាយចាស់ ក៏ដូចជាមិនដឹងអ្វីច្រើនអំពីជីវិតឯកជនរបស់នាយនៅក្រោយគ្រោះថ្នាក់ចរាចរណ៍ដ៏ធំមួយនោះឡើយ។

ក្រោយមកគេទទួលបានសំបុត្រអញ្ជើញសម្រាប់មង្គលការដ៏គួរឱ្យភ្ញាក់ផ្អើលនៅរវាងពេល២សប្ដាហ៍ទៀត។ តែបើតាមសម្ដីក្នុងឆាតនៅពេលនេះ Lorenzoដូចជាមិនអាចរង់ចាំបានដល់ពេលនោះឡើយ។

«អ្នកប្រុសចង់ជួបខ្ញុំបន្ទាន់?»

សំណួរគេផ្ញើមកបង្ហាញថាគេមិនបានរើសមនុស្សខុសក្នុងការជជែកត្រង់ៗជាមួយនាយប៉ះនេះទេ។

វឌ្ឍនៈយល់ចិត្តអតីតចៅហ្វាយពេកហើយចំណែកLorenzoក៏មិនមានអ្វីត្រូវបង្អង់ទៀតដែរ។គេចុចញាប់ដៃនូវពាក្យពេចន៍ក្នុងចិត្ត៖

«ខ្ញុំទើបតែបានជួបជាមួយមនុស្សស្រីម្នាក់!គឺ សន្យា! ខ្ញុំមកផ្ទះវិញមានអារម្មណ៍ថាចម្លែកៗ ជាមួយគេនោះ! ពីរនាក់យើងមិនបាននិយាយអ្វីច្រើន តែគេហាក់ដូចជា ខ្ញុំពិបាកនិយាយទេរបៀបគេមើលមកខ្ញុំ គេមើលទៅដូចជាខូចចិត្តខ្លាំងដែលឃើញរបួសខ្ញុំ បើឱ្យគិត ខ្ញុំយល់ថា គេជាសង្សារខ្ញុំបានសម! តែ គ្រប់គ្នាប្រាប់ថា គេនោះជាមនុស្សមានវិកល !គេនោះកំពុងចង់រារាំងអាពាហ៍ពិពាហ៍របស់ខ្ញុំនិងពិនណា! ខ្ញុំមិនដឹងមួយណាពិត មួយណាកាឡៃ !កាល៥ឆ្នាំមុនបងនៅទីនេះជាមួយខ្ញុំ បងប្រាកដជាដឹងរឿងខ្ញុំច្រើន តែពេលនេះ បងនៅឆ្ងាយ.....!!»

«ស្អែកខ្ញុំឡើងទៅបាងកក!អ្នកប្រុសឈឺ ខ្ញុំមិនឱ្យជិះឆ្ងាយទេ ! ខ្ញុំនឹងទៅភ្នំពេញលួចលាក់ស្កាត់ជួបអ្នកប្រុស! រឿងនេះដឹងតែយើងពីរនាក់!»

Lorenzoហាក់ភ្ញាក់ផ្អើលនឹងសារសម្រេចចិត្តដ៏រហ័សនេះ។ តែគេក៏តបសួរវិញយ៉ាងរហ័សដូចគ្នា៖

«លួចលាក់!»

វឌ្ឍនៈតបវិញរ៉ាវ៖

«ក្មេងស្រីសន្យាជាសង្សារអ្នកប្រុស!»

ចម្លើយអតីតជំនួយការធ្វើឱ្យ គេទច់ដៃដែលប្រុងជះសំណួរទៅបន្ថែម។ គេឈប់ដៃជាមួយស្នូរអ្វីមួយក្នុងបេះដូង។

ហេតុអ្វី?

ហេតុអ្វីពេលការបញ្ជាក់នេះពីមាត់អតីតជំនួយការកាលណា ចិត្តយើងឆាប់ទទួលស្គាល់ភ្លាមថាវាជាការពិត?

ហេតុអ្វីបានជា យើងដូចជាមានបំណងចង់ឱ្យនាងម្នាក់នោះ ចូលមកជាមនុស្សជិតស្និទ្ធរបស់ យើងពិតមែន?

គេលើកដៃចុចទូរសព្ទលែងសរសេរ......

«មិញបងថាម៉េច? សង្សារខ្ញុំមិនមែនពិនណាទេ?!»

វឌ្ឍនៈដកដង្ហើមធំ។

នេះជាលើកដំបូងរវាងពេល៥ឆ្នាំដែលចៅហ្វាយស្រស់សង្ហា ម្នាក់នេះបានលើកទូរសព្ទខលមករកអតីតកូនចៅជំនិត។

គេក៏មិនដឹងដូចគ្នាថាហេតុអ្វីបានជា ក្រោយជារបួស Lorenzoលែងចង់ជួបអ្នកណាហើយចុងក្រោយបង្អស់គេបានទទួលយកការភ្ជាប់ពាក្យរៀបការជាមួយកូនស្រីផ្ទះហិរញ្ញវត្ថុដ៏មានស្តុកនៅភ្នំពេញ?

«អ្នកប្រុស! ខ្ញុំសង្ស័យថា មនុស្សជុំវិញខ្លួនអ្នកប្រុសកំពុងលាក់កំបាំងអ្វីម្យ៉ាងដែលជាការពិតចេញពីជីវិតអ្នកប្រុស! យកល្អយើងជួបគ្នាផ្ទាល់!ខ្ញុំនឹងទៅដល់បាងកកហើយខ្ញុំនឹងទាក់ទងអ្នកប្រុសមុនពេលខ្ញុំជិះទៅទីនោះ គឺកន្លែងដែលអ្នកប្រុសធ្លាប់ជួបក្មេងស្រីឈ្មោះសន្យាកាលពី៥ឆ្នាំមុន!»

«កន្លែងណាទៅ?»

គេសួរយ៉ាងទទូចតែវឌ្ឍនៈដកដង្ហើមធំ ។

នរៈយើង ក៏ដកដង្ហើមធំតាម។ មិនយូរប៉ុន្មានគេក៏និយាយបន្ថែមៈ

«គ្រប់គ្នាមិនឱ្យខ្ញុំស្វែងរកអតីតកាលទេ ពួកគេថាកំណកដុំឈាមក្នុងសរសៃខួរក្បាលខ្ញុំនៅមានច្រើនហើយវាអាចធ្វើឱ្យខ្ញុំពិការបានគ្រប់ពេលបើសិនជាខ្ញុំព្យាយាមគិត!តែបងដឹងទេ កាលដែល រស់នៅដោយមិនស្គាល់ខ្លួនឯង វាដូចជាការបរិភោគអាហារដែលមិនដឹងរសជាតិប្រៃល្វីងហើយមិនដឹងថាហូបដើម្បីអ្វីដែរ!»

វឌ្ឍនៈទប់ចិត្តដែលក្តុកក្តួល គេនិយាយមួយៗពន្យល់ៈ

«អ្នកប្រុសមានសិទ្ធិត្រូវដឹង! ចាំខ្ញុំនិយាយប្រាប់! ៥ឆ្នាំមុនLorenzoបុរសអ្នកមានស្តុកវ័យក្មេងល្ហក់បាននាំជំនួយការឈ្មោះវឌ្ឍនៈម្នាក់នេះចាកចេញមកពីអាមេរិក! លោកបាន ធ្លាប់ជាប់ផុងខ្លួន សឹងរក្សាជីវិតមិនគង់ ក្នុងសំណុំរឿងក្តី ចាប់ពង្រត់កូនស្រីអ្នកមាន៣៥នាក់នៅភ្នំពេញ! នៅថ្ងៃចុងក្រោយពួកប៉ូលិសបានមកដល់ ខ្ញុំបានឱ្យឡានមួយទទួលអ្នកប្រុសនៅក្រោយផ្ទះប៉ុន្តែអ្នកប្រុសឡើងឡានច្រឡំ ដោយពួកពាលចាប់ជំរិតជាអ្នកបញ្ជូនអ្នកប្រុសទៅខេត្តកោះកុងព្រំប្រទល់ព្រៃក្រាស់មួយដែលអ្នកប្រុសបានជួបក្មេងស្រីម្នាក់នោះ! គេជាអ្នកសង្គ្រោះជីវិតអ្នកប្រុស!គេនោះឈ្មោះសន្យាជា ម្ចាស់សាលាជនបទចុងកាត់មួយឆ្ងាយពីផ្សារ ហើយគេដាក់ឈ្មោះសាលារបស់គេថា ផ្ទះអនាគត»

«ផ្ទះអនាគត?»

ឈ្មោះនេះចូលទៅរំញោចបេះដូងអ្នកជំងឺ....តែមាត់នាយនៅតែចចេសបដិសេធ....

«ខ្ញុំនឹកមិនឃើញអ្វីទាំងអស់បង!»

«មិនអីទេអ្នកប្រុស!ពេលយើងជួបគ្នា អ្នកប្រុសនឹងនឹកឃើញ!»

ប្រុសស្អាតនៅស្ងៀមស្ងាត់ផ្ទង់គិតទៅដល់ស្នាមថើបពីម្សិលរបស់នាង ។«បងភ្លេចអស់ហើយLorenzoចម្កួត!»

ប្រលោមលោកនេះមានជាសៀវភៅ តម្លៃ ២៥០០០រៀល

សូមទំនាក់ទំនង ០១៥១៣១១១និង ០១៦២១៣១១១